# សិលាចារឹកវត្តព្រៃមៀន K.១៨

## ១- ព័ត៌មានទូទៅ

នៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា (Inscriptions du Cambodge) ក្បាលទី២ លោក ហ្សក៊ សេដែស បានបញ្ជាក់ថាផ្ទាំងសិលាចារឹកចារនៅលើថ្មស្រទាប់នេះ មានប្រភពមកពីព្រៃមៀន ស្រុកទាំង ខេត្តកំពត[១] បច្ចុប្បន្នត្រូវនឹងទីតាំងវត្តសេរីសោភ័ណ្ឌ ហៅវត្តព្រៃមៀន ស្ថិតនៅក្នុងភូមិព្រៃមៀន ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ។ វត្តនេះសាងនៅលើទីតាំងប្រាសាទឥដ្ឋ ដែលមានកសិន្ធុព័ទ្ធជុំវិញ និងមានផ្លូវចូលពីទិសខាងលិច[២]។ នៅឆ្នាំ ១៨៨៣ លោក អេទីយែន អៃម៉ូនីយេរ បានអានកាលបរិច្ឆេទសិលាចារឹកនេះ និងសង្ខេបខ្លឹមសារចុះផ្សាយក្នុងទស្សនាវដ្ដីអាស៊ី។ ក្រោយមក លោក លុយណេត៍ ដឺឡាហ្សុង គីយែរ នៅក្នុងឆ្នាំ១៩២១ បានរាយការណ៍អំពីសិលាចារឹកនេះមកចៅហ្វាយខេត្តទ្រាំង។ ពីរឆ្នាំបន្ទាប់មក សិលាចារឹកនេះបានយកមករក្សាទុកនៅសារមន្ទីរ អាល់ប៊ែរ សារូត៍ ដែលបច្ចុប្បន្នជាសារមន្ទីរជាតិភ្នំពេញ។ បន្ទាប់មកទៀត ផ្ទាំងសិលាចារឹកនេះ យកទៅរក្សាទុកនៅអភិរក្សដ្ឋានអង្គរ រហូតមកដល់បច្ចុប្បន្ន[៣]។

អត្ថបទចារឹកនេះ មានចុះកាលបរិច្ឆេទនៅថ្ងៃទី៧កើត ខែស្រាពណ៍ មហាសករាជឆ្នាំ៦៤៨ ដែលត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១១ ខែកក្កដា គ្រិស្តសករាជឆ្នាំ៧២៦។ កាលបរិច្ឆេទក្នុងសិលាចារឹកនេះ ប្រើប្រាស់ពាក្យសំស្ក្រឹតលាយនឹងពាក្យប្រាក្រឹត ពុំប្រើប្រាស់សញ្ញាលេខនោះទេ។ ការចុះកាលបរិច្ឆេទដោយប្រើពាក្យសំស្ក្រឹត និង/ឬលាយពាក្យប្រាក្រឹតយើងឃើញមានការពេញនិយមនៅសម័យមុនអង្គរ។ កាលបរិច្ឆេទដែលសរសេរជា **អដ្ឋចត្តាលីគោត្តរមច្ឆត** កើតចេញពីបន្សំពាក្យ **អដ្ឋ** (៨) + **ចត្តាលីគ** (៤០) + **ឧត្តរ** (លើសដោយ) + **ឞដ៊** (៦) + **ឝត** (១០០)។ ពាក្យ **ចត្តាលីគ** ពុំមែនជាពាក្យសំស្ក្រឹតឡើយ ប៉ុន្តែជាពាក្យ

---

[១] ត្រង់ចំណុចទីតាំងនេះ ប្រហែលជាលោក ហ្សក៊ សេដែស អាចមានបញ្ហាគាន់ច្រឡំ ដ្បិតថាទីតាំងនេះ ពុំធ្លាប់ស្ថិតនៅក្នុងដែនខេត្តកំពតទេ(?)។

[២] សូមមើលបន្ថែម៖ https://cisark.mcfa.gov.kh/core/showsite.php?id=794

[៣] សូមអានបន្ថែម៖ ហ្សក៊ សេដែស (១៩៤២) ទំព័រ១៤៦-១៤៨។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ប្រាក្រឹត ដែលត្រូវនឹងពាក្យសំស្ក្រឹតថា **ចត្វា(រ្តា)លីស** មានន័យថា ៤០។ **អម្តចត្តាលីស** មានន័យថា ៤៨, តាមសន្ធិក្នុងភាសាសំស្ក្រឹត **បដិ** + **ឝត** > **បច្ឆត** មានន័យថា ៦០០។

ដោយផ្ទាំងចារឹកនេះបែកជាពីរផ្នែក និងខូចខាតនៅផ្នែកខាងស្តាំ ព្រមទាំងមានភាពសឹករេចរឹលនិងផ្ទាត់ផ្ទៃថ្មដោយអន្ទើៗ ធ្វើឱ្យយើងពុំអាចអានអត្ថបទបានទាំងស្រុងពេញលេញនោះឡើយ។ ត្រង់ចំណុចដែលខូចខាតខ្លះ នាំឱ្យយើងពិបាកយល់អត្ថន័យផងដែរ។ យ៉ាងនេះក្តី យើងនៅតែអាចយល់នូវខ្លឹមសារជារួមបាន គឺអត្ថន័យរបស់សិលាចារឹកនេះ ជាកំណត់ត្រាតង្វាយថ្វាយចំពោះប្រាសាទព្រះគម្តែងអញស្រីសង្ករនារាយណ៍ ដោយអ្នកធ្វើតង្វាយទាំងឡាយមានដូចជា ម្រតាញភាស្ករបាល ម្រតាញសិទ្ធិគណ ម្តាយម្រតាញចន្ទ្រសេនា ជាដើម។ ក្នុងតង្វាយនោះ មានអ្នកបម្រើស្រីប្រុស ខ្លះមានកូនផង និងដីស្រែចម្ការ។ ក្នុងអត្ថបទនេះ ក៏មានពាក្យផ្តាសាដល់នរណាដែលរំលោភព្រះ ឱ្យធ្លាក់ទៅនរក២១ជាន់ផង។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- អម្តចត្តាលីគោត្តរបច្ឆតឝកបរិគ្រហ(ស)ប្តមីកេតិ[គ្រា]

២- វនម្រតាញ៑ភាស្ករបាលឱយស្រែទង៑ក្នុំមិតវ្រះកម្រតា(ង៑)

៣- អញ៑គ្រីឝង្ករណារ[៨]យនបុណ្យម្រតាញ៑ស្រេវ្រែកល្បោរ៑(ជ) ---

៤- ស្រេត្បេងរ៑វិជ២០-១ស្រេក្រៅទ្នលិមាសិ១០-២ស្រេវ្រៃទំពេកិមា(សិ) ---

៥- ស្រេដេងថ្មីងីកន្ទះសរស្រេទ្វ៉ះបក៑មាសិ១ជេ១ស្រេទ្វំលិស(វេ[៩]) ---

៦- ស្រេកន្ទះវ្រៃមាសិ៣-ក្នុំកន្តែកុក្មេរ៑១កោនិ៤កុ(កល្ប)១កុ---

៧- កោនិ១ប្រាបិកោនិ២កុប្រេក៑១កោនិ១ក្ងស៑១កោនិ១កុចំបោត៑១កោ(និ) ---

៨- កុត្ងៃ១កោនិ១(កុ)ទប្ងិបិ១កោនិ១កុស្វេត៑១កោនិ១កុសុវណ៌១កុ---

៩- ចង្កា១កុតំវេ១កុកន្សាញ៑១កុស្មោក៑១កុត្បាញ៑១កុត្រសោ---

១០- កុរំរុះ១ឃោទកញ្ជត៑១រំបត៑១ប្រគស្តគន១តរង្គ---

[៨] ព្យាង្គ «រា» ចារជួសនៅខាងក្រោមចន្លោះព្យាង្គ «ណា» និង «យ»។

[៩] លោក សេដែស (១៩៤២) ពុំបំពេញបន្ថែម។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១១- ទុតិ១កប្បោនិ១អនន្តរាវបិ១គ្គនិ១កញ្ជ១ជម្ន៌គ(ក្តិ១)---

១២- កំបុសិ១ស្មោមិ១ក្ញុំប្រទានម្រតាញសិទ្ធិគនកុកញ្ជ១---

១៣- កុកំវតិ១កុមុលិះ១កោនិ-(ម)ធុប្រីយ១កំ-ានិ១កនិឯតិ[6]១កុ---

១៤- ត្និ--កោនិ១សោចិក្តោ[7]១កោនិ២តួង៏១កោនិ១ប្តាយិ១កោនិ១---

១៥- កោនិ១កន្តេកិ១អំនោយិ១កន្តែបិសោ(តិ)[8]១និម្ត----ង៏១---

១៦- ប្រង៏១-----និ១-----កញ្ចុង៏១---ទោប១ស--១ក្ញោញិ---

១៧- ចន្ទ្រគុប្ត----------តិ១---ក្ញោញិសម្របុ១កោនិ១ត---

១៨- កោនិ១ចង្កា១កោនិ១សល្ប-១កោនិ១អវស--១កន្ទុ[9]១វោ---

១៩- ស្រមោលិ១វ្ជ១--្ន----ក្សូ១ត្មេកិ១កនិអសិ១កនិ---

២០- វ្ជ១កោនិ១កញ្ជែ១កញ្ជ.......(គ/ក)ក្តិមាទ្រ[10]១ត្ងប១ត្បាសិ[11]១(កន្ទា[12])ង៏១---

២១- ---------ជ្យ(យុ)គល(យោ)--ទំរិង៏១គិនេះ[13]ស្រេទង៏ក្ញុំ-------

២២- (កន្តែម្រតាង៏)ទង៏គេ[14]ក្ញោញិអ្នេម្រតាញិចន្ទ្រសេនដោនិតវ្រះកម្រតា(ង៏អញ)

២៣- (ត្រីគង្កូរ)ណាវាយនបុណ្យម្រតាញិទង៏គេក្ញោញគេតិ[15]-----

២៤- យ---នៅអ្នកិតនិវស្តតិអំរិលាង៏វ្រះ--ឯការីគ(និរយ)---

២៥- តនាំ-----បំនោសិបំផុះវ្រះកម្រតាង៏អញិគិតនាគិ---

២៦- កុវា-----កោនិកុ----កិ១កុ-----វកិ១កុក-----ទ------១វាក--

---

[6] លោក សេដែស (១៩៤២) អានជា «កនិឯកិ»។

[7] លោក សេដែស (១៩៤២) អានជា «កុ»។

[8] លោក សេដែស (១៩៤២) អានជា «កន្តែបិសាតិ»។

[9] លោក សេដែស (១៩៤២) អានជា «កន្ទ្យ»។

[10] លោក សេដែស (១៩៤២) ពុំអានព្យាង្គ «មាទ្រ»។

[11] លោក សេដែស (១៩៤២) អានជា «ត្បសិ»។

[12] លោក សេដែស (១៩៤២) ពុំអានព្យាង្គនេះទេ។

[13] លោក សេដែស (១៩៤២) ពុំអាន «ជ្យ(យុ)គល(យោ)--ទំរិង៏១គិនេះ» ឃ្លានេះទេ។

[14] លោក សេដែស (១៩៤២) ពុំអាន «(កន្តែម្រតាង៏)ទង៏គេ» ឃ្លានេះទេ។

[15] លោក សេដែស (១៩៤២) ពុំអាន «គេក្ញោញគេតិ» ឃ្លានេះទេ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

២៧- វាក------វ១កុសម្រំបុ១កោនិកនិទិបិ១វា-----

២៨- គិល-----១វា(អំ)វៅ១មិត្រគណ១កុអសា-----១------

២៩- ស្រេជំនាហ្វ---អបិទងក្ញោញប្រក្កព្វកន្ទះវ្រៃ-----

៣០- គិស្រេជំនាហ្វផោង------មាសិ៥គិនេះក្នុំទង-----

៣១- -----ញិតវ្រះកម្រតាងអញគ្រីគង្ករ[នារាយណ]

## ៣- អត្ថបទប្រែសម្រួល

(១-១២) (នា)មហាសករាជឆ្នាំ៦២៨ ទី៧កើត ខែស្រាពណ៍ ម្រតាញកាស្តរបាល ថ្វាយស្រែនិងអ្នកបម្រើចំពោះព្រះគម្តែងអញស្រីសង្ករនោរាយណ៍ ជាបុណ្យរបស់ម្រតាញ។ (ស្រែមាន) ស្រែព្រៃកល្បៅ(ទំហំ)--វិជ ស្រែត្បែង(ទំហំ)២១វីជ ស្រែក្រៅទ្នល(ទំហំ)១២មាស ស្រែព្រៃទំពោក(ទំហំ)--មាស ស្រែដើងស្ទឹងកន្ទះសន្រែ ស្រែរទេះបាក់(ទំហំ)១មាស ១ជើ ស្រែរទល(ទំហំ) --សន្រែ ស្រែកន្ទះព្រៃ(ទហំ)៣មាស។ អ្នកបម្រើស្រី(មាន)នាងក្មេរ១ (និង)កូន៤(នាក់) នាងកល្ប១ នាង---(និង)កូន១ (នាង)ប្រាបកូន២(នាក់) នាងប្រេក១ (និង)កូន១(នាក់) (នាង)ក្រឹស១ (និង)កូន១(នាក់) (នាង)ចំបោត១ (និង)កូន-(នាក់) នាងត្វេម១ (និង)កូន១(នាក់) នាងទប្និប១ (និង)កូន១(នាក់) នាងស្វេត១ (និង)កូន១(នាក់) នាងសុវណ្ណ១ នាង---ចង្កា១ នាងតំវេ១ នាងកន្សាញ១ នាងស្វោក១ នាងត្បាញ១ នាងត្រសោ--- នាងវំរុះ១។ (អ្នកបម្រើ)ប្រុស កញ្ចត១ រំបត១ ប្រគស្តគន១ តវង្គ---១-ទុត១ កញ្ចោន១ អនន្តរាប១ ត្តន១ កញ្ច១ ធម្មសក្តិ១--- កំបុស១ ស្មោម១។

(១២-២០) អ្នកបម្រើជាតង្វាយរបស់ម្រតាញសិទ្ធិគន (មាន)នាងកញ្ច១--- នាងកំវត១នាងមុលិះ១ (និង)កូន(១នាក់) នាង(ម)ធុប្រិយ១ នាងកំ-ាន១ (នាង)កនឯត១ នាង---ត្និ--(និង)កូន១(នាក់) នាងសោចក្តោ១ (និង)កូន២(នាក់) (នាង)ត្វង១ (និង)កូន១(នាក់) នាងប្តាយ១ (និង)កូន១(នាក់)--- (និងកូន)១(នាក់) (នាង)កន្តេក១ (នាង)អំនោយ១ (នាង)កន្តែបិសោត១ (នាង)និស្ត----ង១ ---ប្រង១ -----ន១ -----កញ្ចុង១ ---ទោស១ ស--១ ក្ញោញ---បន្ទ្រគុប្ត----------ត១--- ក្ញោញសម្របុ១ (និង)កូន១(នាក់) ត---(និង)កូន១(នាក់) ចង្កា១ (និង)

កូន១(នាក់) សល្ប-១ (និង)កូន១(នាក់) អវស--១ កន្ទុ១ វៅ---ស្រមោល១ វេ្ង១ --ុ----ក្សូ១ ត្រេក១ កន្ទស១ កន--- វេ្ង១ (និង)កូន១(នាក់) កញ្ជែ១ កញ្ជ.......(ស/ក)ក្តិមាទ្រ១ ត្រីស១ ត្បាស១ កន្ទាង១---។

(២១) ---------ជ្យ(សម្បៀក)យុគលយោ--ដំណាំ១។

(២១-២២) ទាំងនេះគឺស្រែនិងអ្នកបម្រើ------- ករិយាម្រតាងនិងអ្នកជាក្ញោញ(ដែល)ម្ដាយម្រតាញចន្ទ្រសេនា ថ្វាយចំពោះព្រះគម្តែងអញស្រីសង្ករនារាយណ៍ (គឺជា)បុណ្យរបស់ម្រតាញនិងអ្នកជាក្ញោញ គឺ-----។

(២២) នូវអ្នកដែលធ្វើឱ្យនិរាស គឺរំលាងព្រះ (សូមធ្លាក់ទៅ)នរក២១ជាន់។

(២៥) និយាយអំពីអ្នកបួសធ្វើពិធប្រោះទឹកនៅប្រាសាទ----

(២៦-២៨) បញ្ជីឈ្មោះអ្នកបម្រើ

(២៩) ស្រែដែលជាវ---រួមទាំងក្ញោញប្រាក់ឯកន្ទះព្រៃ-----

(៣០) គឺស្រែដែលជាវផ្សេងទៀត-----(ទំហំ)៥មាស

(៣០-៣១) ទាំងនេះគឺខ្ញុំបម្រើនិងស្រែ (ដែលថ្វាយចំពោះ)ព្រះគម្តែងអញស្រីសង្ករនារាយណ៍។

## បញ្ជីឯកសារ

Cœdès, George. (1942). Inscription de Prei Mien. In *Inscription du Cambodge* (Vol. II, pp. 146-148). Paris: Editions de Boccard.

Website: https://cisark.mcfa.gov.kh/core/showsite.php?id=794

# បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹកវត្តព្រៃមៀន (រូបថត៖ EFEO & CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកវត្តព្រៃមៀន (រូបថត៖ EFEO & CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកវត្តព្រៃមៀន (រូបថតៈ EFEO & CISARK)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



ព្រះវិហារវត្តព្រៃមឿន (រូបថត៖ ហ្វេសប៊ុកវត្តសេរីសោភ័ណ្ឌ ហៅព្រៃមឿន)



ព្រះវិហារវត្តព្រៃមឿន (រូបថត៖ ហ្វេសប៊ុកវត្តសេរីសោភ័ណ្ឌ ហៅព្រៃមឿន)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង